# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តបន្ទាយមានជ័យ**

លេខៈ.........១៧០០/១៦ .សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ
## នៅរដ្ឋបាលខេត្តបន្ទាយមានជ័យ

## អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៤ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការត្រាស់បង្គាប់តែងតាំងជាអភិបាលនៃគណៈអភិបាលខេត្ត បន្ទាយមានជ័យ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាគណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោមៈ

១-ឯកឧត្តម **សួន បវរ** អភិបាលនៃគណៈអភិបាលខេត្ត ប្រធាន

អាសយដ្ឋានៈ ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ (Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com , mean.vannak@bmc.ncdd.gov.kh ,Web : www.bmc.ncdd.gov.kh

| | | |
|---|---|---|
| ២-លោក **អ៊ុំ រាត្រី** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣-លោក **នៅ ចំរើន** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក **ឈឿន ប៉ៃគ្រយ៉ុង** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥-លោក **ប៊ីង គឹមសឹង** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៦-លោក **យុត ស្វិនី** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧-លោក **ង៉ែ កេងលី** | អភិបាលនៃគណៈអភិបាលក្រុងសិរីសោភ័ណ | សមាជិក |
| ៨-លោក **ង៉ោ ម៉េងជ្រួន** | អភិបាលនៃគណៈអភិបាលក្រុងប៉ោយប៉ែត | សមាជិក |
| ៩-លោក **ឡុង ពុន** | អភិបាលនៃគណៈអភិបាលស្រុកមង្គលបូរី | សមាជិក |
| ១០-លោក **សាន ស៊ានហូ** | អភិបាលនៃគណៈអភិបាលស្រុកអូរជ្រៅ | សមាជិក |
| ១១-លោក **អែម សុខា** | អភិបាលនៃគណៈអភិបាលស្រុកម៉ាឡៃ | សមាជិក |
| ១២-លោក **ឃូ ពៅ** | អភិបាលនៃគណៈអភិបាលស្រុកស្វាយចេក | សមាជិក |
| ១៣-លោក **ប្លែក វ៉ារី** | អភិបាលនៃគណៈអភិបាលស្រុកថ្មពួក | សមាជិក |
| ១៤-លោក **លី សុវណ្ណារិទ្ធ** | អភិបាលនៃគណៈអភិបាលស្រុកព្រៃនេត្រព្រះ | សមាជិក |
| ១៥-លោក **យឹម សំណាង** | អភិបាលនៃគណៈអភិបាលស្រុកភ្នំស្រុក | សមាជិក |
| ១៦-លោក **ណាង ឌុទ្ធី** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១៧-លោក **ម៉ុក ចន្ទពុទ្ធា** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | សមាជិក |
| ១៨-លោក **ឈាន សុធា** | ប្រធានការិ.មន្ទីរមុខងារសាធារណៈខេត្ត | មន្ត្រីបង្គោល |

**ប្រការ ២**.-

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តបន្ទាយមានជ័យ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្រ្ត និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈ រវាងរដ្ឋបាលខេត្ត ជាមួយលេខាធិការដ្ឋាននៃគណៈ កម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្រ្ត និងសកម្មភាពការងារកែទម្រង់រដ្ឋបាល សាធារណៈ
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែ ទម្រង់រដ្ឋបាលសាធារណៈ ជូនប្រធានស្ថាប័នសាមីជាប្រចាំ
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារ ត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោល ក្នុងការស្វែងរក និងប្រមូលព័ត៌មាន

ការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍ សង្ខេបនូវសូចនាករ ដែលទាក់ទងទៅនឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត មកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឬ នាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ ។ ជាពិសេសមន្ត្រីបង្គោល ត្រូវចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ ៣.-**

នាយករដ្ឋបាល នាយកទីចាត់ការ ប្រធានអង្គភាពចំណុះសាលាខេត្ត ប្រធានមន្ទីរមុខងារសាធារណៈខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

បន្ទាយមានជ័យ ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ២០១៦

**អភិបាលខេត្ត**

**សួន បវរ**

**កន្លែងទទួល៖**

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-ក្រុមប្រឹក្សាខេត្ត

«ដើម្បីគោរពជូនជ្រាប»

-ដូចប្រការ៣

-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈ ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ (Phone-Fax) ០៥៤ ៧១០០៦២ Email: banteaymeanchey1@gmail.com , mean.vannak@bmc.ncdd.gov.kh ,Web : www.bmc.ncdd.gov.kh